ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៨៣ សប្តាហ៍ទី ២ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

348.033
CAM

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៤-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥២៧ ស្តីពីការផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក ផាក ឌូយ៉ុង (PARK DO YOUNG) ជនជាតិកូរ៉េ សញ្ញាតិកូរ៉េ កើតនៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា ផាក ឌីហុក (PARK DYHOK) ៩១២០

២៤-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥២៨ ស្តីពីការផ្តល់សញ្ញាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់អ្នកស្រី ស៊ុយ ស៊ី (SU SI) ជនជាតិឥណ្ឌូណេស៊ី សញ្ញាតិឥណ្ឌូណេស៊ី កើតនៅ SARI BINTA UJARA ប្រទេសឥណ្ឌូណេស៊ី ៩១២១

២៩-១០-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១០០៧/៥៤៤ ស្តីពីការផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក ហ ជេយ៉ុង (HEO JAE YOUNG) ជនជាតិកូរ៉េ សញ្ញាតិកូរ៉េ កើតនៅសូវ សាធារណរដ្ឋកូរ៉េ ៩១២២

០៣-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៥២ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និងអស់លោក ចំនួន ០៥ រូប ៩១២៣

០៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៥៤ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ២៨ រូប ៩១២៤

០៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៥៥ ស្តីពីការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈចំពោះសពឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត ឡុង សៀម នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ៩១២៦

០៧-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៥៦ ស្តីពីការដាក់ឱ្យចូលនិវត្តន៍ ឧត្តមសេនីយ៍ត្រី ឈុប ឈាត ក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩១២៧

០៧-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៥៥៧ ស្តីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សាម្ភួន ជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩១២៨

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

០៨-១១-២០០៧	-អនុក្រឹត្យលេខ ១៦៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៩១២៩
០៨-១១-២០០៧	-អនុក្រឹត្យលេខ ១៧០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៩១៣១
០៨-១១-២០០៧	-អនុក្រឹត្យលេខ ១៧១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា	៩១៣៣
០៥-១១-២០០៧	-អនុក្រឹត្យលេខ ៨៩២ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៩១៣៥
០៥-១១-២០០៧	-អនុក្រឹត្យលេខ ៨៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៩១៣៨
០៧-១១-២០០៧	-អនុក្រឹត្យលេខ ៨៩៤ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៩១៣៩
០៧-១១-២០០៧	-អនុក្រឹត្យលេខ ៨៩៥ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ	៩១៤១
០៧-១១-២០០៧	-អនុក្រឹត្យលេខ ៨៩៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៩១៤២
០៧-១១-២០០៧	-អនុក្រឹត្យលេខ ៨៩៧ អនក្រ.តត ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍	៩១៤៤
០៨-១១-២០០៧	-អនុក្រឹត្យលេខ ៨៩៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៩១៤៥
០៨-១១-២០០៧	-អនុក្រឹត្យលេខ ៨៩៩ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា	៩១៤៦
០៨-១១-២០០៧	-អនុក្រឹត្យលេខ ៩០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៩១៤៧
០៨-១១-២០០៧	-អនុក្រឹត្យលេខ ៩០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៩១៤៩
០៨-១១-២០០៧	-អនុក្រឹត្យលេខ ៩០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៩១៥០
០៨-១១-២០០៧	-អនុក្រឹត្យលេខ ៩០៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	៩១៥២
០៨-១១-២០០៧	-អនុក្រឹត្យលេខ ៩០៤ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា	៩១៥៤

២.សេចក្តីសំរេច

០៨-១១-២០០៧	-សេចក្តីសំរេចលេខ ៦០ សសរ ស្តីពីការបង្កើតក្រុមការងារដើម្បីដឹកនាំ គ្រប់គ្រងទីប្រឹក្សាជំនួយការ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	៩១៥៦

៣.សារាចរណែនាំ

០៨-១១-២០០៧	-សារាចរណែនាំលេខ ០៦ សរណន ស្តីពីការអនុវត្តផែនការបែងចែកសម្បទានដីសង្គមកិច្ច	៩១៥៨

III. ការិយាល័យក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ប្រកាស

០៦-១១-២០០៧ -ប្រកាសលេខ ០៤២ អបស/ម.ព ស្តីពីការសរសេរផ្លាកសញ្ញាសំគាល់ថ្មី សំរាប់មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ និង អង្គភាពដែលទទួលពិគ្រោះ ឬ ព្យាបាលជម្ងឺ ៩១៦០

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភា ស៊ីន** ៩១៦៣

១៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ៃឌីប្រាន់ (ខេមបូឌា) លីមីធីត** ៩១៦៥

១៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចន់ ធីរៈ ស៊ីធីស** ៩១៦៧

១៥-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ូម៉ុក (ខេមបូឌា)** ៩១៦៩

១៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាច ហ្វុង** ៩១៧១

១៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១០៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាន យ៉ាង** ៩១៧៣

១៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១០០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីស្វូល ខនស្ត្រាក់សិន** ៩១៧៥

១៦-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.ប៊ី.អិន ឌីវេឡុបមេន** ៩១៧៧

១៩-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល ឌី អាយ** ៩១៧៩

២០-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.អេ.អិម.ឌី.ខូ លីមីធីត** ៩១៨១

នស/រកត/១០០៧/៥២៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ផាក ឌូយ៉ុង (PARK DO YOUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៦២ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា ផាក ឌីហុក (PARK DYHOK) ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

៣៧៧.០៧១០.៥៥៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៧

លេខ: ៥៦១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៧.
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនកេន

នស/រកត/១០០៧/៥២៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រ អោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់អ្នកស្រី ស៊ុយ ស៊ី (SU SI) ជនជាតិឥណ្ឌូណេស៊ី សញ្ជា ឥណ្ឌូណេស៊ី កើតថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៧៥ នៅ SARI BINTAN UJARA ប្រទេសឥណ្ឌូណេ

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយ សំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

៣៣ស.០៧១០.៥៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧

លេខ ៩១២ ច.ល
ចំលងចេញពីច្បាប់ដើម
... ថ្ងៃទី ... ខែ វិច្ឆិកា ឆ្នាំ ២០០៧
... ទីស្តីការគណៈរដ្ឋមន្ត្រី ... រាជរដ្ឋាភិបាល
... ខេន

ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៥៤៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ហោ ជេយ៉ុង (HEO JAE YOUNG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៨៣ នៅសូវ សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១០.៥៧៣

លេខ: ៥១៣ ចល
ថតចំលងចែក
ភ្នំពេញ ថ្ងៃទី ០១ ខែ ១១ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៧

ស៊ុន ជិនតេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៥២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :
១- ឯកឧត្តម មាស ប៉ូ
២- លោក លី ប៊ុនធឿន
-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :
១- លោក ហោ ឡឹម
២- លោក ប៊ុនប៉ា ម៉ារីស៊ូច
៣- លោក គាត រស្មី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧១១.៥៨១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥៦២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ម៉ានិត

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

១- លោកវរសេនីយ៍ឯក ខៀវ សាម៉ន អត្តលេខ ០៣០៤
២- លោកវរសេនីយ៍ឯក ឡុង វិចិត្រ អត្តលេខ ០៣០៦
៣- លោកវរសេនីយ៍ឯក ហេង សែម អត្តលេខ ០២៤៥
៤- លោកវរសេនីយ៍ឯក ពិន ពិសិដ្ឋ អត្តលេខ ០៣៦៥
៥- លោកវរសេនីយ៍ឯក ជុំ សំរាត អត្តលេខ ០២៤៤
៦- លោកវរសេនីយ៍ឯក សៅ ម៉ុនធឿន អត្តលេខ ០២២៨
៧- លោកវរសេនីយ៍ឯក នួច ហ៊ិន អត្តលេខ ០៣៤៥
៨- លោកវរសេនីយ៍ឯក ប្រាក់ ការុណារ៉ា អត្តលេខ ០១៦៥
៩- លោកវរសេនីយ៍ឯក ទាវ សាវ៉ាន អត្តលេខ ០១៧៦
១០- លោកវរសេនីយ៍ឯក ឡាច យឺន អត្តលេខ ០១៧៧
១១- លោកវរសេនីយ៍ឯក ឃិន សុវណ្ណ អត្តលេខ ០០៨៣
១២- លោកវរសេនីយ៍ឯក នូ ឡៀន អត្តលេខ ០១៩៥

ROYAUME DU CAMBODGE * LE ... ROYAL

១៣- លោកវរសេនីយ៍ឯក ម៉ៅ និម្មល អត្តលេខ ០២០០
១៤- លោកវរសេនីយ៍ឯក ពៅ ឈីមមី អត្តលេខ ០២១៥
១៥- លោកវរសេនីយ៍ឯក ម៉ុក ម៉ុនឈាង អត្តលេខ ០២១៧
១៦- លោកវរសេនីយ៍ឯក ម៉ោញ កំសាន្ត អត្តលេខ ០២២១
១៧- លោកវរសេនីយ៍ឯក ដាម សារ៉ាយ អត្តលេខ ០២៤២
១៨- លោកវរសេនីយ៍ឯក យ៉ឹម ចេង អត្តលេខ ០១៧០
១៩- លោកវរសេនីយ៍ឯក មុំ សាមាន អត្តលេខ ០១២២
២០- លោកវរសេនីយ៍ឯក ឡេង ហ៊ី អត្តលេខ ០១១៣
២១- លោកវរសេនីយ៍ឯក ហ៊ាន សារឿន អត្តលេខ ០៩៥៩
២២- លោកវរសេនីយ៍ឯក ឌឹម សារឿន អត្តលេខ ០១៨៩
២៣- លោកវរសេនីយ៍ឯក ម៉ក់ សំអុល អត្តលេខ ០១៥៧
២៤- លោកវរសេនីយ៍ឯក ឡៀម សារ៉ាយ អត្តលេខ ០៣៦៣
២៥- លោកវរសេនីយ៍ឯក ឌុច ឡឿន អត្តលេខ ០២៦៩
២៦- លោកវរសេនីយ៍ឯក អ៊ុច សារុន អត្តលេខ ០២៦៤
២៧- លោកវរសេនីយ៍ឯក តែ ជួងសុផល អត្តលេខ ០២៣៦
២៨- លោកវរសេនីយ៍ឯក ឆូ សារី អត្តលេខ ០២៣៥ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៧.០៧១១.៥៨៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥២០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧
[illegible] ខាធិការ [illegible] រដ្ឋាភិបាល
[illegible] ជិនកេន

នស/រកត/១១០៧/៥៥៥

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះសព

ឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត ឡុង សៀម

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៧១១.៥៨៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥២១ ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់អោយចូលនិវត្តន៍ឧត្តមសេនីយ៍ត្រី **ណុប ណរាត** អត្តលេខ ០០២៦ ក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយមានប្រសិទ្ធភាពនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧១១.៥៩៥

លេខ ៤២៤ ច.ល
ជំរាបជូនចេក
... ថ្ងៃទី ... ខែ ... ឆ្នាំ២០០៧
អគ្គលេខាធិការ... រាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

យុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សាមួន អត្តលេខ ០០០១២៩ ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១១.៥៨៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ:៥៧៥ ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឌិនកេន

'2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ...១២៥...អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការផ្ទេរតំណាងនាងចរិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០ និងត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្ដីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្ដីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- យោងលិខិតលេខ ២៥២៨ ព.ណ.គន ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧ របស់ក្រសួងពាណិជ្ជកម្ម ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ១ : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួនៈ ២០០.០០០.០០០រៀល (ពីររយលានរៀលគត់) ពីជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) មកជំពូក ៦០ (ការទិញ) ជូនក្រសួងពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

ប្រការ២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែងរបស់ក្រសួងពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

ប្រការ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាស រដ្ឋធម្មនុញ្ញ បន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែ រាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាស ដោយព្រះរាជក្រមលេខ ១០/នស /៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាស ដោយព្រះរាជក្រម លេខ នស/រកម /១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូ កែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦ /០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែ នាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤០១ សហវ.ប្រក . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំ ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។
- បានឃើញប្រកាសលេខ ១៤១៧ សហវ.ថហ. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរ ស្តីពីការបែងចែកចំណាយ ឥណទានថវិកាផ្ទៃក្នុងជំពូក គណនី អនុគណនី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- យោងលិខិតលេខ ៤០៨៣ អយក.ហវ . ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ របស់ក្រសួងអប់រំ យុវជន និង កីឡា

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាមិនមែនកម្មវិធីចំនួន ៣.៩៣៤.០០០.០០០រៀល (បីពាន់ប្រាំបួនរយសាមសិបបួនលានរៀលគត់) ពីជំពូក ៦៤ (បន្ទុកបុគ្គលិក) មកជំពូក ៦០ (ការទិញ) ចំនួន ៨២៩.០០០.០០០រៀល (ប្រាំបីរយម្ភៃប្រាំបួនលានរៀលគត់) , ជំពូក ៦១ (សេវាខាងក្រៅ) ចំនួន ៨២០.០០០.០០០រៀល (ប្រាំបីរយម្ភៃលានរៀលគត់) និង ជំពូក ៦២ (សេវាខាងក្រៅផ្សេង១) ចំនួន ២.២៨៥.០០០.០០០រៀល (ពីរពាន់ពីររយប៉ែតសិបប្រាំលានរៀលគត់) ដើម្បីបំពេញតំរូវការចំណាយចាំបាច់ របស់ក្រសួងអប់រំ យុវជន និង កីឡា (ផ្នែកអប់រំ) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា ២ : ការបែងចែកឥណទានចំណាយថវិកាផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែង របស់ក្រសួងអប់រំ យុវជន និង កីឡា ក្នុងឆ្នាំ ២០០៧ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡាត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
- ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីក្រាបបង្គំជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...១៧១.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មៈ បន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែ ដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ,ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកា លេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទ របស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋា មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៧២.៤៤០.០០០ រៀល (ចិតសិបពីរលានបួនរយសែសិបពាន់រៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន ២១.១៤០.០០០ រៀល និង មកជំពូក ៦៤ (បន្ទុកបុគ្គលិក) ចំនួន ៥១.៣០០.០០០ រៀល ជូនក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយបើកសវនាការជាសាធារណៈដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នភាព និង ការចុះឈ្មោះបោះឆ្នោត សំរាប់ការបោះឆ្នោតជាតិឆ្នាំ ២០០៨ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៩៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រី បុគ្គលិក ចំនួន ៥១ រូប ដែលបានខិតខំបំពេញភារកិច្ច ជូនជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសការងារ :

១-លោក	ឡា	ជាតុឡា	អគ្គលេខាធិការរង គ.ជ.ប
២-លោក	ឡោ	ឡាក់	អនុប្រធាននាយកដ្ឋានប្រតិបត្តិការ ទទួលបន្ទុកកស្តុភារ
៣-លោក	គឹម	ហុង	ប្រធាន គខ/កប ខេត្តកណ្តាល
៤-លោក	លឹម	ចាន់សំ	ប្រធាន គខ/កប ខេត្តសៀមរាប
៥-លោក	ហួត	ផុន	ប្រធាន គខ/កប ក្រុងព្រះសីហនុ

ខ_មេដាយប្រាក់ការងារ :

១-លោកស្រី	វណ្ណ	វាសនា	ជំនួយការលោកជំទាវ អនុប្រធាន គ.ជ.ប
២-លោក	គង់	សុផាត	ប្រធានការិយាល័យវិទ្យុទាក់ទង
៣-លោក	ចាន់	មុនីជាតិ	ប្រធានការិយាល័យផែនការ និងប្រតិបត្តិការ
៤-លោក	មិន	គឹមលុន	ជំនួយការសមាជិក គ.ជ.ប
៥-លោក	គៀន	ថៃ	ជំនួយការសមាជិក គ.ជ.ប
៦-លោក	សំ	ឫទ្ធី	ជំនួយការសមាជិក គ.ជ.ប

៧-លោក	ហ៊ី	គិនសៀង	មន្ត្រី បទបញ្ជា និង នីតិវិធី
៨-លោក	ចាន់	ទ៊ាត	មន្ត្រី បទបញ្ជា និង នីតិវិធី
៩-លោក	ឡុង	ស៊ានអួន	ប្រធានការិយាល័យ គណនេយ្យ
១០-លោក	ហ៊ី	គីមសេង	ប្រធាន គខ/កប ខេត្តបន្ទាយមានជ័យ
១១-លោក	ហែម	សិលា	អនុប្រធាន គខ/កប ខេត្តបាត់ដំបង
១២-លោក	សុខ	ឈិន	អនុប្រធាន គខ/កប ខេត្តកំពង់ចាម
១៣-លោក	អ៊ុង	ទិសាល	អនុប្រធាន គខ/កប ខេត្តកំពត
១៤-លោក	ប្រាក់	ម៉ូច	អនុប្រធាន គខ/កប ខេត្តក្រុងភ្នំពេញ
១៥-លោក	ទទ្យ	សោភ័ណ្ឌ	អនុប្រធាន គខ/កប ខេត្តព្រៃវែង
១៦-លោក	ឯម	គូរិបុត្រ	អនុប្រធាន គខ/កប ខេត្តពោធិ៍សាត់
១៧-លោក	ពៅ	សាខន	អនុប្រធាន គខ/កប ខេត្តសៀមរាប
១៨-លោក	ឯម	សុគ	អនុប្រធាន គខ/កប ខេត្តស្វាយរៀង
១៩-លោក	គីម	ម៉ិនណាង	អនុប្រធាន គខ/កប ខេត្តតាកែវ

គ-មេជាយសីវិទ្ធភារចារ :

១-លោកស្រី	ណាខន	សេរីវត្ន	គណនេយ្យករ
២-លោកស្រី	ផេង	សុខលីន	មន្ត្រីប័ណ្ណសារ ខុទ្ទកាល័យ គ.ជ.ប
៣-លោក	ទី	នរៈ	លេខាធិការ ខុទ្ទកាល័យ គ.ជ.ប
៤-លោក	ទែម	ថូ	លេខាធិការ សមាជិក គ.ជ.ប
៥-លោកស្រី	ចំនួ	តារា	លេខាធិការ សមាជិក គ.ជ.ប
៦-លោក	[illegible]	គីរុណ	ការីកុំព្យូទ័រ អគ្គលេខាធិការ
៧-លោក	អ៊ុក	វ៉ាណេត	អនុប្រធានការិយាល័យ ទទួលបន្ទុកបូកសរុបរបាយការណ៍
៨-លោកស្រី	ចាន់	តារា	មន្ត្រីទទួលការងារបៀវត្ស
៩-លោក	នួច	រចនា	មន្ត្រីទទួលការងារបុគ្គលិក
១០-លោក	ឈី	ទីរៈ	មន្ត្រីតំកល់ឯកសារ និងនាំសារ
១១-លោក	ម៉ឺន	សំអុល	មន្ត្រីគ្រប់គ្រងទឹកភ្លើង ទូរស័ព្ទ និងឧបករណ៍បំពងសម្លេង
១២-លោក	ផេង	ឡុយ	មន្ត្រីគ្រប់គ្រងទឹកភ្លើង ទូរស័ព្ទ និងឧបករណ៍បំពងសម្លេង
១៣-លោក	សួន	សៅសត្យា	អនុប្រធានការិយាល័យផែនការ និងប្រតិបត្តិការ
១៤-លោក	ស៊ួន	សោម	អនុប្រធានការិយាល័យភស្តុភារ និងឃ្លាំង
១៥-លោក	សៀង	ម៉ិនលី	អនុប្រធានការិយាល័យដឹកជញ្ជូន និងសន្តិសុខ
១៦-លោក	ចៅ	សុខជួន	មន្ត្រីទទួលបន្ទុកការងារទូទៅ នៃមជ្ឈមណ្ឌលកុំព្យូទ័រ
១៧-លោក	ឡេង	និត្យវិបុលសម្បត្តិ	មន្ត្រីបូកសរុបបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត
១៨-លោកស្រី	តាន់	ស៊ិនឌូ	មន្ត្រីចងក្រងឯកសារ និងពិនិត្យឯកសារបណ្តុះបណ្តាល
១៩-លោក	ហ៊ិន	សេន	មន្ត្រីចងក្រងឯកសារ បណ្តុះបណ្តាល
២០-លោក	តន់	សារ៉ា	មន្ត្រីបញ្ជូនព័ត៌មានតាមហ្វាក់ ហ្វូន អ៊ីមែល និង វែបសាយ

២១-លោក	ម៉ៃ	សារី	មន្ត្រីប្រមូលព័ត៌មាន
២២-លោក	គួចទាវ៉ា	ម៉ូរី	គណនេយ្យករ
២៣-លោកស្រី	គ្រី	តាំងសៀក	មន្ត្រីត្រួតពិនិត្យ និងអធិការកិច្ចហិរញ្ញវត្ថុ
២៤-លោក	គង់	យសតារា	មន្ត្រីត្រួតពិនិត្យ និងអធិការកិច្ចហិរញ្ញវត្ថុ
២៥-លោក	ព្រាំ	សុខហេង	មន្ត្រីត្រួតពិនិត្យ និងអធិការកិច្ចហិរញ្ញវត្ថុ
២៦-លោកស្រី	ស្រី	ឆេតសារ៉ាត់	មន្ត្រីសារពើភ័ណ្ឌ
២៧-លោក	អ៊ុក	សារុន	មន្ត្រីទទួលកិច្ចការគណបក្ស និងអ្នកសង្កេតការណ៍

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>**កន្លែងទទួល :**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៣

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសសឹង្ហបូរី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **Andrew Tay Teng Yew** អ្នកគ្រប់គ្រងសណ្ឋាគារ **HIMAWARI** នៅកម្ពុជា បានជួយឧបត្ថម្ភលើការស្នាក់នៅ ហូបចុក និងសំបុត្រយន្តហោះដល់សិល្បករកម្ពុជា ចំនួន១០នាក់ ដែលបានចូលរួមសំដែងបុណ្យ **Visak Festival** នៅប្រទេសសឹង្ហបូរី កាលពីថ្ងៃទី ២៦ ខែ ឧសភា ដល់ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៧ កន្លងទៅនេះ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសសឹង្ហបូរី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយ ទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>**កន្លែងទទួល :**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨១៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **គឹម នៃហៀង** មន្ត្រីក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ជាអភិបាលរងខេត្តសៀមរាប ជំនួសឯកឧត្តម **ចំឡ សំអាន** ។

មាត្រា ២ : លោក **គឹម នៃហៀង** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

ព្រះបរមរាជវាំង

ខាធិការដ្ឋានព្រឹទ្ធសភា

ខាធិការដ្ឋានរដ្ឋសភា

ខាធិការរាជរដ្ឋាភិបាល

ល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

ប្រការ ៤

កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៨៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានផ្ទេរភារកិច្ចឯកឧត្តម ចំនួ សំអាន ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៤ ពីអភិបាលរងខេត្តសៀមរាប ឱ្យមកជាអភិបាលរងក្រុងភ្នំពេញ ជំនួសលោក ខុន ស៊ា ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៣៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក ឈឿង សុផាត ឋានន្តរសក្តិ វរសេនីយ៍ឯក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលរងខេត្តកំពង់ស្ពឺ ជំនួសលោក ឯក ម៉ូ ដែលចូលនិវត្តន៍ ។

មាត្រា ២ : លោក ឈឿង សុផាត ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិក នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៩*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៨៩៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល ឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដាក់ឱ្យលោក ឯក ម៉ូ ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៧ អភិបាលរងខេត្តកំពង់ស្ពឺ ចូលនិវត្តន៍ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧១៣៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ស្រេង ម៉ាច់** ជាជំនួយការឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើប្រធាននាយកដ្ឋាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..៨៩៥..អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយសុវត្ថារា

ខ្ព

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន០៣រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈលើគ្រប់វិស័យ នៅស្រុកតំបែរ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

១-លោក	**ជួន**	**មិត្តថុល**	នៅរាជធានីភ្នំពេញ
២-លោក	**នីង**	**ពិសិដ្ឋ**	អភិបាលស្រុកតំបែរ
៣-លោក	**មាស**	**សឿន**	នៅរាជធានីភ្នំពេញ

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រភេទ និងជូនសប្បុរសជន ចំនួន ២៥រូប ដែលបានបរិច្ចាគធនធាន ជួយកសាងព្រះវិហារ សាលារៀន និង សមិទ្ធផលជាច្រើនទៀត នៅវត្តស្រម៉រ ក្នុងឃុំទឹកជ្រៅ ស្រុកតំបែរ ខេត្តកំពង់ចាម ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ ឌិត សឿន អនុគណស្រុកតំបែរ បច្ច័យចំនួន ១៥.០០០ ដុល្លារ

២-ព្រះតេជគុណ ហាន រី ចៅអធិការវត្តស្រម៉រ បច្ច័យចំនួន ១៤.០០០ ដុល្លារ

៣-លោក ឃ្លោក សំអាន នៅរាជធានីភ្នំពេញ ថវិកាចំនួន ១៣.០០០ ដុល្លារ

៤-លោក សុខ មុន្នីរតនា នៅរាជធានីភ្នំពេញ ថវិកាចំនួន ១២.០០០ ដុល្លារ

៥-លោក ឡុង ឌុន នៅរាជធានីភ្នំពេញ ថវិកាចំនួន ១២.០០០ ដុល្លារ

៦-លោក ហេង ម៉េងហាក់ នៅរាជធានីភ្នំពេញ ថវិកាចំនួន ១២.០០០ ដុល្លារ

៧-លោក ស្រី សុចិត្រ នៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

៨-លោក ទិន កុសល នៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

៩-លោក នាដ្ឋ វ៉ាឌុន នៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

១០-លោក សយ សុផាត នៅរាជធានីភ្នំពេញ ថវិកាចំនួន ១០.០០០ ដុល្លារ

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក ប្រាជ្ញ សារឿន នៅរាជធានីភ្នំពេញ ថវិកា ចំនួន ៥.៥០០ ដុល្លារ

២-លោក ធឿន តីរុណ នៅរាជធានីភ្នំពេញ ថវិកា ចំនួន ៥.៥០០ ដុល្លារ

៣-លោក	ម៉ី	លីហួត	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៥.៥០០ ដុល្លារ
៤-លោក	ប្រាក់	សម្បត្តិ	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៥.០០០ ដុល្លារ
៥-លោក	ឌិន	ផល្លាប	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៥.០០០ ដុល្លារ
៦-លោក	ឆាន់	សាំង	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៥.០០០ ដុល្លារ

គ. មេដាយសេរីវឌ្ឍស្ថាបនាជាតិ :

១-លោក	ឡិក	ដាលី	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៣.៥០០ ដុល្លារ
២-លោក	ហ៊ូ	គា	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៣.៥០០ ដុល្លារ
៣-លោក	ជា	ស៊ីវុត្ថា	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ៣.០០០ ដុល្លារ
៤-លោក	កើត	កិត្តិនាថ	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២.២៥០ ដុល្លារ
៥-លោក	ខៀវ	ចិសិដ្ឋ	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២.០០០ ដុល្លារ
៦-លោក	សារុន	សម្បត្តិ	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២.០០០ ដុល្លារ
៧-លោក	ចែម	ផល្លា	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២.០០០ ដុល្លារ
៨-លោក	សេក	ហ៊ាន	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២.០០០ ដុល្លារ
៩-លោក	ផា	សីហា	នៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២.០០០ ដុល្លារ

មាត្រា២ះ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩០៦ អនក្រ.តត

អនុក្រឹត្យ

ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ

៣៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧0៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

